ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
គណៈកម្មាធិការលទ្ធកម្ម
លេខ : ៧០ អយក.គល.ទន

# សេចក្តីជូនដំណឹង
## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ
## ការផ្គត់ផ្គង់ប្រេងឥន្ធនៈគ្រប់ប្រភេទសម្រាប់ឆមាសទី២ឆ្នាំ២០១៨

ក្រសួងអប់រំ យុវជន និងកីឡា សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ក្រសួងអប់រំ យុវជន និងកីឡា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់ប្រេងឥន្ធនៈគ្រប់ប្រភេទសម្រាប់ឆមាសទី២ ឆ្នាំ២០១៨ ថវិកាកម្មវិធីឆ្នាំ២០១៨ ផ្នែកអប់រំ និង ផ្នែកឧត្តមសិក្សា ជំពូក៦០-៦០០១-៦០០១៥ កម្មវិធីទី៥ អនុកម្មវិធីទី១០ ចង្កោមសកម្មភាពទី១ របស់អង្គភាពថវិកានាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ កម្មវិធីទី២ អនុកម្មវិធីទី១៤ ចង្កោមសកម្មភាពទី១ និង២ របស់អង្គភាពថវិកាវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល កម្មវិធីទី២ អនុកម្មវិធីទី៤ ចង្កោមសកម្មភាពទី១ របស់អង្គភាពថវិកានាយកដ្ឋានឧត្តមសិក្សា ។

កិច្ចលទ្ធកម្មនេះនឹងត្រូវបានធ្វើឡើង តាមរយៈវិធីសាស្រ្តការដេញថ្លៃប្រកួតប្រជែងក្នុងស្រុក ក្រោមច្បាប់ និងស្របតាមបទបញ្ញត្តិលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃក្រសួងអប់រំ យុវជន និងកីឡា ដែលមានអាសយដ្ឋានអគាររដ្ឋបាលថ្មី(សាលាបឋមសិក្សាចៅពញាហុក) ជាន់ទីពីរ ផ្លូវលេខ៣៨០ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ៖ ០២៣ ២១០ ៤៦៤ /០២៣ ២២០ ៥២៧ ទូរស័ព្ទ/ទូរសារលេខ៖០២៣ ២១៥ ២០២ អ៊ីមែល: procurement@moeys.gov.kh គេហទំព័រ www.moeys.gov. kh/procurement ចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ ។

អ្នកដេញថ្លៃត្រូវភ្ជាប់មកជាមួយឯកសារដេញថ្លៃនូវ **លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ** ដែលមានទឹកប្រាក់ចំនួន **១០ ៦៥៤ ៥០០រៀល (ដប់លាន ប្រាំមួយរយហាសិបបួនពាន់ ប្រាំរយរៀលគត់)** ចេញដោយអគ្គនាយកដ្ឋានរតនាគារ ជាតិ រតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដែគូ (មានទម្រង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅវេលាម៉ោង ០៧: ០០នាទី ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០១៨ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មតាមអាសយដ្ឋានខាងលើនៅ វេលាម៉ោង ០៧: ៥០ នាទីរសៀល ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០១៨។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម តាមរយៈអាសយដ្ឋានខាងលើ ដើម្បីទិញឯកសារ ដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ សុក្រ ១៣ កើត ខែ អស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០១៨
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ- កាលប្បវត្តិ